ថ្ងៃថ្ងៃព្រហស្បត៍ទី៩ខែសីហាម៉ោង៩.៣០នាទីព្រឹកមានបើកការប្រជុំនៅពហុកីឡាដ្ឋានរវាងអគ្គលេខាធិការអ៊ិនគឹមស្រ៊ុននិងក្រុមចំរើសជាតិនិងគ្រូបង្វឹកស្តីអំពីផែនការនៃការប្រកួតថ្នាក់អន្តរជាតិក្នុងឆ្នាំនេះនិងរឿងថវិការបស់សហាពន្ធ័។

<u>របៀបវារៈ៖</u>

១ ថវិកា

២ ស្ពុនស័រ(sponsor)

៣ របាយការណ៏ពីជើងឯកអាស៊ីនៅម៉ាលេស៊ី

៤ គណៈកម្មាធិការប្រតិបត្តិ

៥ ការអញ្ជើញឯកឧត្តមឌុយឃៅចូលសហាពន្ធ័វិញ

៦ ផ្សេងៗ

<u>១ ថវិកា:</u> លោកស្រ៊ុនយកបញ្ហាអំពីការប្រើប្រាស់លុយរបស់ក្រសួងអប់រំយុវជននិងកីឡាដោយបាមបញ្ជាក់ថាការប្រើប្រាស់មិនមែនចេះតែប្រើតាមចិត្តរបស់សហាពន្ធ័ទេ។ មួយជំហានមួយជំហាននៃការប្រើប្រាស់ត្រូវតែគោរពតាមផ្លូវដែលក្រសួងចេញឲ្យដើរទោះបីជាយើងជាសហាពន្ធ័កីឡាឯករាជ្យក៏ដោយ។ទល់នឹងពេលនេះថវិកាឆ្នាំ២០១៨ដែលត្រូវឲ្យសហាពន្ធ័យកទៅប្រើនៅមិនទាន់ធ្លាក់មកដល់ទេ។ ការរៀបចំធ្វើវគ្គបណ្តុះបណ្តាលទាំងផ្ទៃប្រទេសមិនអាចអនុវត្តិបានដូចពេលវេលាដែលសហាព័ន្ធគ្រងទុក។ លោកស្រ៊ុនបានបន្ថែមថាបន្តិចទៀតដាច់ឆ្នាំហើយបើថវិការធ្លាក់មកយឿតយ៉ាវយើងត្រូវតែថវិកានោះឲ្យអស់មុនដាច់ឆ្នាំបើ

មិនដូចឆ្នោះទេគេនឹងយកលុយដែលសល់នោះមកវិញ។ លោកស្រ៊ុនបានបន្ថែមទៀតថាតើឲ្យយើងអាចរៀបចំឡើងវិញនូវផែនការរបស់យើងយ៉ាងដូចម្តេចឲ្យបានមុនដាច់ឆ្នាំបាន?វាជាការមួយយ៉ាងពិបាក!ខ្ញុំត្រូវមានពេលវេលាយ៉ាងច្រើនដើម្បីរៀបចំផែនការមួយៗ។

២ ស្ពុនស័រ(sponsor)

លោកស្រ៊ុនបានអធិបាយបន្តរទៀតថាទល់នឹងពេលនេះយើងពុំទាន់មានស្តុងស័រទេ កាលពីឆ្នាំមុនៗយើងស្រួលរកស្ពុនស័រពីព្រោះយើងមានសហការី២នាក់ក្នុងសហពន្ធ័គេមានជំនាញខាងការរកលុយ ឥឡូវនេះលោកទាំងពីរបានលាឈប់ពីដំណែងក្នុងសហព័ន្ធហើយ ម្នាក់ចូលនិវត្តន៏និងម្នាក់ទៀតសុំលាលែងពីដំណែងជាអគ្គហេរញ្ញឹកក៏ប៉ុន្តែនៅក្នុងប្រតិបត្តិដ៏ដែល។

លោកស្រ៊ុនបានបន្តរថានេះជារឿងមួយដ៏សោកស្តាយដែលយើងបានបាត់រូបអ្នកសំខាន់ទាំងពីរនាក់នោះ។

លោកស្រ៊ុនបន្ថែមថា គាត់មិនសូវមានជំនាញខាងការរកស្តុងស័រទេហើយគាត់បានដើររកដោយអស់ពេលវេលាយ៉ាងច្រើនតែលទ្ធផលនៅតែអវិជ្ជមានដ៏ដែល។ ឥឡូវនេះទឹកឡើងដល់ច្រមុះហើយបន្ថែមលោកស្រ៊ុនយើងមានតែមធ្យោបាយមួយទេគឺទទូចសុំសហការីចាស់ទាំង២នាក់ហ្នឹងឲ្យជួយបើសិនជាលោកមានពេលវេលាហើយមានសុខភាពល្អ។លោកស្រ៊ុនបានសុំឲ្យកីឡាករជំរើសជាតិទាំងអស់ព្រមទាំងគ្រូបង្វឹកជួយផ្តិតមេដាយលើសារសំណូមពរមួយដែលគាត់សរសេរក្នុងនាមរបស់គាត់នឹងក្នុងនាមរបស់អ្នកកីឡាជំរើសជាតិនឹងគ្រូបង្វឹកផ្ញើទៅឲ្យឯកឧត្តមឌុយ ឃៅដោយសូមអញ្ជើញគាត់មកជួយសហព័ន្ធ។អង្គប្រជុំបានយល់ព្រមជាឯកច្ឆ័ន្ទក្នុងករណីនេះ។

បន្ថែមទៅទៀតលោកស្រ៊ុនបានអំពាវនាវឲ្យមិត្តដែលលេងប៊ូលទាំងអស់ជួយរកស្ពុងស័រឲ្យផង បើរកបានគាត់នឹងជូននូវប្រាក់ចំនួន២០ភាគរយពីប្រាក់ឧបថមទាំងនោះជាការអរគុណ។

<u>៣ របាយការណ៍ពីជើងឯកអាស៊ីនៅប្រទេសម៉ាលេស៊ី</u>

ក្នុងករណីនេះលោកអគ្គលេខាធិការបានជំរាបអង្គប្រជុំថា៖យើងត្រូវបានមេដាយមាសមួយបើសិនជាកីឡាការនីនៃប្រទេសចិនតាយប៉ិកក្នុងពេលដែលជួបកីឡាការនី កែ ឡេងរបស់យើង ក្នុងវគ្គពាក់កណ្តាលផ្តាច់ព្រាត់មិនមានខ្មោចចូលទេនោះ នឹងត្រូវចាញ់ កែ ឡេង ព្រោះកែឡេងវាយល្អរហូតក្នុងការប្រកួតជើងឯកអាស៊ីនេះ។

<u>៤ គណៈកម្មាធិការប្រតិបត្តិ</u>

លោកអគ្គលេខាធិការ អ៊ិនគឹមស្រ៊ុន បានបន្ថែមទៀតថាតាមធម្មតាគេត្រូវប្រជុំ៣ខែម្តងប៉ុន្តែយើងមិនអាចធ្វើបានទេឆ្នាំនេះព្រោះយើងមានសមាជិកដល់ទៅ២០នាក់ហើយត្រូវបង់លុយដល់សណ្ឋាគារនៃការស្នាក់នៅ,ថ្លៃបាយនិងថ្លៃធ្វើដំណើររបស់សមាជិកដែលនៅឆ្ងាយព្រមទាំងប្រាក់ហោប៉ៅជូនដល់សមាជិកទាំងអស់។ ដោយសារតែថវិកាយើងស្តួចស្តើងពេកគ្មានលទ្ធភាពដល់ការប្រជុំច្រើនដងរួចអាស្រ័យទៅលើការពិបាកក្នុងការសម្រេចឲ្យទាន់ពេលនៃការងាររបស់អគ្គលេខាធិការគាត់គិតឃើញថាត្រូវបន្ថយឲ្យប្រជុំ១ឆ្នាំតែម្តងវាគ្រប់គ្រាន់ហើយសំរាប់ឆ្នាំនេះ។

<u>៥ ការអញ្ជើញឯកឧត្តមឌុយ ឃៅឲ្យចូលសហពន្ធ័វិញ</u>

លោកស្រ៊ុនបានបន្ថែមក្នុងរឿងនេះថាយើងត្រូវការឯកឧត្តមឌុយ ឃៅក្នុងសហាពន្ធ័វិញព្រោះឯកឧត្តមមានការពិសោធខាងហ្នឹង។កាលពីមុនពេលឯកឧត្តមនិងលោកសូគាចូលរួមជាសកម្មយើងដោះស្រាយបញ្ហារឿងថវិកានេះយ៉ាងស្រួល។យើងមិនអាចចាំគណៈកម្មាធិការប្រតិបត្តិឲ្យជួយដោះស្រាយរឿងនេះបានទេពីព្រោះសមាជិកម្នាក់ៗគេរវល់ក្នុងការងាររបស់គេ។

លោកស្រ៊ុនបន្ថែមទៀតថាលោកបាននិយាយផ្ទាល់នឹងសមាជិកខ្លះសុំឲ្យជួយរកថវិការឲ្យផងប៉ុន្តែមិនបានជាវិជ្ជមានទេ។

<u>៦ ផ្សេងៗ</u>

លោកស្រ៊ុនបានសុំយោបល់ពីអង្គប្រជុំមុននឹងបិទប្រជុំ។លោកគ្រូបង្វឹកសុកម៉ុងបានបញ្ចេញនូវយោបល់របស់លោកអំពីរឿងនេះដោយមានសំណូមពរឲ្យយើងទាំងអស់គ្នាស្រុះស្រួលគ្នាជួយគ្នាមិនថាថ្នាក់លើឬថ្នាក់ក្រោម។

**អ្នកកត់កំណត់ហេតុ**

នាង សាប់បា

អគ្គលេខាធិការរង